**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## ប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍

## ថ្ងៃ អង្គារ ទី ១២ ខែ សីហា ឆ្នាំ ២០១៤ នៅសាលប្រជុំ អ.ជ.ប.ជ.អ

នៅវេលាម៉ោង ៩:០០ ព្រឹក ថ្ងៃច័ន្ទ ទី ១២ ខែ សីហា ឆ្នាំ ២០១៤ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម វេជ្ជបណ្ឌិត តែងគន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានការចូលរួមពី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាន នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

### ១. សមាសភាពចូលរួម:

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ មានអគ្គលេខាធិការរង ប្រធាននាយកដ្ឋានអនុប្រធាននាយកដ្ឋាន សរុបទាំងអស់ ចំនួន ១៦រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម)។

### ២. អវត្តមាន

១-លោកស្រីវេជ្ជ. ងិន លីណា ប្រធាននា. PMER (ប្រជុំ steering committee NSP)

២-លោកវេជ្ជ. អ៊ឹង សុវណ្ណះ អនុប្រធាននា.PMER (សុំច្បាប់ឈឺ)

### ៣. ប្រធានបទនៃកិច្ចប្រជុំ៖

៣.១. ពិភាក្សាលើរបាយការណ៍វឌ្ឍនភាពដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមករបស់នាយកដ្ឋាននីមួយៗ

៣.២. ពិភាក្សាលើផែនការសកម្មភាពដែលត្រូវអនុវត្តនៅក្នុងសប្តាហ៍បន្ទាប់របស់នាយកដ្ឋាននីមួយៗ

៣.៣.សំណូមពរ និងប្រធានបទផ្សេងៗ

## ៤. ដំណើរការ និងលទ្ធផលនៃការប្រជុំ ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ។

មុននឹងឆ្លងចូលដល់ប្រធានបទទី១ ឯកឧត្តមប្រធានបានជូនអង្គប្រជុំ ពិនិត្យជាទូទៅលើកំណត់ហេតុនៃកិច្ចប្រជុំសប្តាហ៍មុន មុននឹង ប្រគល់វេទិកាទៅនាយកដ្ឋាននីមួយៗ ធ្វើរបាយការណ៍វឌ្ឍនភាពកាលពីសប្តាហ៍មុន និងផែនការ សកម្មភាព ដែលត្រូវអនុវត្តនៅសប្តាហ៍នេះ និងសប្តាហ៍បន្ទាប់ទៀត។

### ៤.១. នាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន (CRM Dept) ៖

#### *៤.១.១-សកម្មភាពក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់*

**ឯកឧត្តមវេជ្ជ. ស៊ឹម គឹមសាន បានរាយការណ៍ជូនអង្គប្រជុំទាក់ទងនឹងការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់ដូចខាងក្រោមរួមមានៈ**

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអេដស៍ឃុំ-សង្កាត់ ដែលគ្រោងធ្វើចំនួន៥ខេត្ត ប៉ុន្តែនាយកដ្ឋានរង់ចាំខាងនាយកដ្ឋានហិរញ្ញវត្ថុជូនដំណឹង ពីការអនុម័តថវិការបស់មូលនិធិសាកលសិន។

### ៤.១.២ អនុសាសន៍:

ទាក់ទងនឹងការងាររបស់ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន ឯកឧត្តមប្រធានអង្គប្រជុំបានជូនជាអនុសាសន៍ដូចខាងក្រោមៈ

- ស្នើឯកឧត្តមប្រធាននាយកដ្ឋានរៀបចំឯកសារដូចខាងក្រោម៖

  ១-របៀបវារៈកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ

  ២-របៀបវារៈសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

  ៣-រៀបចំសារនិងរបៀបវារៈត្រូវធ្វើទៅខេត្តសំរាប់រៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

## ៤-២ នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ (PMER Dept)៖

### ៤.២.១-សកម្មភាពក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់:

**លោកស្រីវេជ្ជ. ស៊ូ សុភី បានរាយការណ៍ជូនអង្គប្រជុំទាក់ទងនឹងការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់ដូចខាងក្រោមរួមមានៈ**

- ការរៀបចំគំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ឆ្នាំ២០១៦-២០២០ បានដំណើរការការងារដូចខាងក្រោមៈ

  -បានរៀបចំ Concept note & ToRs for SRA & NSPIV, និង ToRs for SRA & NSPIV consultant

  -បានបង្កើតគណៈកម្មការ Steering committee និងបានរៀបចំប្រជុំតាមការកំណត់

  -បានរៀបចំ ToR for core group និងបានរៀបចំលិខិតស្នើសុំមន្ត្រីខាងផែនការ១

រូបមានដូចជាបណ្តាក្រសួងពាក់ព័ន្ធ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ PLHA MARP ដើម្បីចូលរួមក្នុង core group NSPIV development។

-បានចូលរួមក្នុងកិច្ចប្រជុំ steering committee NSPIV

-បានបង្កើតគណៈកម្មការ និង questionnaire សំរាប់ជ្រើសរើសទីប្រឹក្សាបច្ចេកទេស សំរាប់ការរៀបចំការងារ NSPIV។

- បាននិងកំពុងរៀបចំចងក្រងរបាយការណ៍ទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាល មេរោគអេដស៍និងជំងឺអេដស៍ប្រចាំត្រីមាសទី២ដោយសារមានក្រសួងនិងខេត្តមួយចំនួនបញ្ចូលទិន្នន័យពុំមានភាពច្បាស់លាស់ទាមទារអោយក្រុមការងារធ្វើការទំនាក់ទំនងសុំការបញ្ជាក់។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបានត្រៀមរៀបចំ សិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តសូន្យបី សំរាប់សមាជិកគណៈកម្មាធិការអេដស៍ឃុំ-សង្កាត់ ដែលនឹងគ្រោងធ្វើនៅថ្ងៃទី២៦-២៩ ខែសីហា ឆ្នាំ២០១៤ នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង តាមការជូនដំណឹងរបស់ PR ថាត្រូវផ្អាករង់ចាំការអនុម័តលើ training plan from Global Fund Geneva សិនយោងតាមលិខិតចុះថ្ងៃទី១៤ កក្កដា។
- បានរៀបចំលិខិតផ្ញើទៅតាមបណ្តាក្រសួងជាសមាជិក ដើម្បីអោយចាត់បញ្ជូនឈ្មោះតំណាងមួយរូបមកចូលរួមក្នុងក្រុមការងារស្នូល នៃការរៀបចំផែនការយុទ្ធសាស្រ្តជាតិទូលាយទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ឆ្នាំ២០១៦-២០២០។
- បានចូលរួមប្រជុំជាមួយ PR ពិនិត្យលើរបាយការណ៍ត្រីមាស២ និងរៀបចំឡើងវិញនូវឯកសារគាំទ្រដល់របាយការណ៍សកម្មភាពសំរាប់ត្រីមាសទី២ ។
- បានចុះអភិបាលទៅបណ្តាស្ថាប័នទទួលជំនួយបន្តរង (SSRs) ទាំង៣ មានដូចជា ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា។

- រៀបចំឯកសារទាក់ទងនឹងការកាត់បន្ថយថវិកាមូលនិធិសកល ផ្អែកលើលិខិតចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ របស់ CCC។
- ចូលរួមកិច្ច និងធ្វើបទបង្ហាញអំពីការកាត់ថវិកាមូលនិធិសកល នៅក្នុងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងថវិកាជំនួយជាមួយស្ថាប័នទទួលជំនួយបន្តរង (SSRs)ទាំង៣ ។
- បានរៀបចំកាត់បន្ថយលើថវិកាចំនួន ៥០% នៃខ្ទង់ Training category ទៅតាមការណែនាំរបស់ PR និងបានធ្វើជូនថ្នាក់ដឹកនាំពិនិត្យមុននឹងបញ្ជូន training plan នេះ ទៅ PR ។

**៤.៣. នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ** (PCS Dept) ៖

**៤.៣.១-សកម្មភាពក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់:**

**លោកវេជ្ជ. យង់ សុវណ្ណនា បានរាយការណ៍ ជូនអង្គប្រជុំទាក់ទងនឹងការងារដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់ដូចខាងក្រោមរួមមានៈ**

- នាយកដ្ឋានមានសកម្មភាពជាច្រើនត្រូវអនុវត្តក្នុងគំរោងមូលនិធិសាកលនៅក្នុងខែសីហានេះ។ ខាងបច្ចេកទេសបានរៀបចំរួចរាល់តែត្រូវ ជូនដំណឹងពីនាយកដ្ឋានហិរញ្ញវត្ថុថាត្រូវរង់ចាំរហូតដល់មានការអនុម័តពីខាងមូលនិធិសាកលនៅ Geneva សិន បើយោងតាមលិខិតចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤។

**៤.៤. នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ** (Admin & Finance Dept) ៖

**៤.៤.១-សកម្មភាពក្នុងសប្តាហ៍នេះ និងសប្តាហ៍បន្ទាប់:**

**លោក ឈឹម ឃិនដារ៉េត បានរាយការណ៍ជូនអង្គប្រជុំទាក់ទងនឹងការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសប្តាហ៍បន្ទាប់ ដូចខាងក្រោមរួមមានៈ**

- បានរៀបចំរបាយការណ៍PUDR7 និងបានដាក់ជូនថ្នាក់ពិនិត្យ និងចុះហត្ថលេខាផ្ញើទៅ PR
- បានរៀបចំធ្វើ shortlist មុខដំណែង accountant assistant
- បានរៀបចំឯកសារ និងបានផ្សព្វផ្សាយសំរាប់ជ្រើសរើសទីប្រឹក្សាបច្ចេកទេស SRA & NSPIV
- បានរៀបចំកិច្ចប្រជុំជាមួយ SSRs កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៤.៤.២ អនុសាសន៍:**

ទាក់ទងនឹងការងាររបស់ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ឯកឧត្តមប្រធានអង្គប្រជុំបានជូនជាអនុសាសន៍ដូចខាងក្រោមៈ

- ស្នើរៀបចំឯកសារចំនុចសំខាន់ទាក់ទងនឹងសារាចរណ៍ណែនាំរបស់ក្រសួងហិរញ្ញវត្ថុដាក់ជូនថ្នាក់ដឹកនាំនិងត្រូវជំរាបជូននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ។
  - លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរៀបចំឯកសារសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម៖

    ១-រៀបចំលិខិតសំរាប់អញ្ជើញសម្តេចនាយករដ្ឋមន្ត្រីចូលរួមក្នុងទិវាអេដស៍១ធ្នូ

    ២-រៀបចំបញ្ជីឈ្មោះអ្នកចូលរួម

    ៣-រៀបចំការងារពាក់ព័ន្ធនឹងការផ្គត់ផ្គង់និងថវិកា

**៥. សំណូមពរ និងប្រធានបទផ្សេងៗ:**

**ឯកឧត្តមប្រធានអង្គប្រជុំ** បានលើកឡើងថា មានរៀបចំប្រជុំថ្នាក់ដឹកនាំ នៅថ្ងៃទី១៤ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមអគ្គលេខាធិការស្នើ លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ រៀបចំលិខិតអញ្ជើញ និងរបៀបវារៈកិច្ចប្រជុំអញ្ជើញប្រធានថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អោយបានមុនពេលប្រជុំ។

**ឯកឧត្តមប្រធានអង្គប្រជុំ** បានលើកឡើងនាយកដ្ឋាន CRM និងរដ្ឋបាល និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ស្នើឯកឧត្តមប្រធាននាយកដ្ឋាន CRM រៀបចំឯកសារដូចខាងក្រោម៖

  ១-របៀបវារៈកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ

  ២-របៀបវារៈសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

  ៣-រៀបចំសារ និងរបៀបវារៈត្រូវផ្ញើទៅខេត្តសំរាប់រៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍។

- ស្នើលោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ រៀបចំឯកសារសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម៖

  ១-រៀបចំលិខិតអញ្ជើញសម្តេចនាយករដ្ឋមន្ត្រីចូលរួមក្នុងទិវាអេដស៍ពិភពលោក

  ២-រៀបចំបញ្ជីឈ្មោះអ្នកចូលរួម

  ៣-រៀបចំការងារផ្គត់ផ្គង់ និងថវិកា

**ឯកឧត្តមស៊ឹម គឹមសាន** បានលើកឡើងទាក់ទងម៉ាស៊ីនត្រជាក់អត់ត្រជាក់ស្នើលោកប្រធាននាយកដ្ឋានជួយដោះស្រាយជុសជុលដើម្បីអោយបានត្រជាក់អាចអង្គុយធ្វើការបាន។លោកប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុបានបំភ្លឺថាលោកបានដោះស្រាយជុសជុលរួចហើយនៅតែមិនត្រជាក់ដោ

យសារតែម៉ាស៊ីនត្រជាក់ភាគច្រើនខូចត្រូវការបំពាក់ម៉ស៊ីនថ្មី។លោកដារ៉េតជំរាបថាលោកបានលើកសំណើទិញម៉ាស៊ីនត្រជាក់នៅក្នុងគំរោងផែនការថវិកាជាតិឆ្នាំ២០១៥។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១:00 នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែលប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤

| | | |
|---|---|---|
| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យ | របាយការណ៍រៀបចំដោយ |
| អគ្គលេខាធិការ | អនុប្រធាននាយកដ្ឋាន | |
| | | សៀក សុភ័ក្រ្ត |
| ឯកឧត្តមវេជ្ជ. តែង គន្ធី | លោកស្រីវេជ្ជ. ស៊ូ សុភី | |